# កិច្ចប្រជុំប្រចាំឆ្នាំ លើកទី៣៣ នៃសមាជិកអង្គការ គ.ស.ក

**ថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣** (ព្រឹកម៉ោង ៨:៣០ ដល់ ១២:០០)

នៅសណ្ឋាគារ រ៉ាហ្វ៊ល ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ

## ១- សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពឈានមុខគេ ដែលមានសមាជិកទាំងអង្គការជាតិ និងអង្គការបរទេសនៅកម្ពុជា ហើយបានដើរតួនាទីយ៉ាងសំខាន់ ចាប់តាំងពីឆ្នាំ១៩៩០។ អង្គការ គ.ស.ក មានតួនាទី និងធ្វើកិច្ចការយ៉ាងសកម្មជាងបីទស្សវត្សរ៍ ក្នុងនាមអង្គការសង្គមស៊ីវិល ដើម្បីបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល អភិបាលកិច្ចស្ថាប័ន និងគណនេយ្យភាព ក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព នៃដំណើរអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាពនៅកម្ពុជា។ ក្នុងដំណាក់កាលបច្ចុប្បន្ន នៃកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP ២០២១-២០២៣) ដំណាក់កាលទីបួន ក្រោមទស្សនៈវិស័យ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា ហើយមានគោលដៅធំពីរ៖ ១) ការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និង២) ការបំពេញមុខងារប្រកបដោយនិរន្តរភាព នៃមជ្ឈមណ្ឌលធនធានសម្រាប់សង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីអបអរសាទរនូវតួនាទីយ៉ាងសំខាន់នេះ ក្នុងការសម្របសម្រួល និងគាំទ្រ សម្រាប់អង្គការសមាជិកភាព និងភាពជាដៃគូ កិច្ចប្រជុំប្រចាំឆ្នាំនឹងត្រូវរៀបចំឡើង ជាព្រឹត្តិការណ៍ចម្បងសម្រាប់សមាជិកភាព ដៃគូ និងតួអង្គអភិវឌ្ឍសំខាន់ៗ ដើម្បីចែករំលែក ពិភាក្សា និងស្វែងរកការឆ្លើយតបសមស្រប សម្រាប់សកម្មភាពបន្ត។ ស្របតាមលក្ខន្តិកៈ កិច្ចប្រជុំប្រចាំឆ្នាំនេះ នឹងត្រូវបានធ្វើឡើង ដើម្បីពិនិត្យឡើងវិញនូវការងារកន្លងមក ព្រមទាំងពិភាក្សា និងរៀនសូត្រសម្រាប់ផែនការការងារឆ្នាំបន្ត។ សម្រាប់កម្មវិធីនេះ នឹងប្រារព្ធឡើង **នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣** ។

អ្នកចូលរួមប្រមាណជិត ២០០នាក់ មកពីអង្គភាពផ្សេងៗ ដែលជាអង្គការសមាជិកអង្គការ គ.ស.ក ដៃគូសង្គមស៊ីវិល វិស័យឯកជន និងតួអង្គអភិវឌ្ឍន៍ផ្សេងៗ*(តំណាងមន្ត្រីរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ ស្ថាប័នផ្សេងៗ តំណាងអង្គការសហគមន៍មូលដ្ឋាន និងក្រុមយុវជន ជាដើម)* នឹងត្រូវបានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស។

## ២- គោលបំណង

- ទទួលស្គាល់នូវការចូលរួមគាំទ្ររបស់អង្គការសមាជិកភាព និងដៃគូ អបអរសមិទ្ធផល និងថ្លែងអំណរគុណ ក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍនៅកម្ពុជា
- ឆ្លុះបញ្ចាំងពីសកម្មភាពការងារឆ្នាំកន្លងទៅ ផែនការបន្តសម្រាប់ការអនុវត្តការងារការ និងគណៈគ្រប់គ្រង សម្រាប់គណៈកម្មាធិការប្រតិបត្តិ
- ធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូ កិច្ចការបណ្តាញ និងសហប្រតិបត្តិការ សម្រាប់អង្គការសមាជិក ដៃគូម្ចាស់ជំនួយ បណ្តាញអង្គការខេត្ត និងដៃគូរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយនិរន្តរភាពនៅកម្ពុជា។

## ៣- របៀបវារៈ

| ម៉ោង | ប្រធានបទ | អ្នកសម្របសម្រួល និងវាគ្មិន |
|---|---|---|
| ៨:៣០ – ៩:០០ | **ការចុះឈ្មោះចូលរួម និងទំនាក់ទំនង** | អង្គការ គ.ស.ក និង អ្នកចូលរួម |
| ៩:០០ | **ការប្រកាសកម្មវិធី និងគោរពភ្លេងជាតិ** | អ្នកកាន់កម្មវិធី៖ **អ្នកស្រី ប្រាក់ កែវគង្គា**<br>**លោក ជា វិបុល** |
| ៩:០៥ | **របាំជូនពរ** | **ក្រុមរបាំ** |
| ៩:១០ – ១០:០០ | **<u>សុន្ទរកថាស្វាគមន៍ ខ្លឹមសារគន្លឹះ និងបើកកម្មវិធី</u>**<br>• **សុន្ទរកថាស្វាគមន៍**<br>• **សារគន្លឹះបើកកម្មវិធី ពីតំណាងក្រសួងមហាផ្ទៃ** | ▪ **អ្នកស្រី ជី សុជាតិ** ប្រធានគណៈកម្មាធិការប្រតិបត្តិ និងជានាយិកាប្រចាំប្រទេស អង្គការអន្តរជាតិបំរើសុខភាពប្រជាជន<br>▪ **ឯកឧត្តម ឈឹម កាន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃក្រសួងមហាផ្ទៃ |
| ១០:០០ – ១០:៣០ | **ថតរូប សម្រាកអាហារសម្រន់  និងកសាងទំនាក់ទំនង** | អ្នកចូលរួមទាំងអស់ |
| ១០:៣០ – ១០:៤០ | **កម្មវិធីកំសាន្ត  ដោយក្រុមរបាំ ណាឌី** | **សម្តែងដោយក្រុមរបាំ ណាឌី** |
| ១០:៤០ – ១១:១០ | **<u>ប្រកាសជាផ្លូវការ</u>៖ គណៈកម្មាធិការប្រតិបត្តិថ្មី ២០២៣-២០២៤**<br>• សារគន្លឹះពីមេរៀនសំខាន់ៗរបស់គណៈកម្មាធិការប្រតិបត្តិចប់អាណត្តិ<br>• ចំណាប់អារម្មណ៍ ការតាំងចិត្ត និងសារគន្លឹះជាយុទ្ធសាស្រ្តការងារជាមួយអង្គការសមាជិក ពីគណៈកម្មាធិការប្រតិបត្តិថ្មី | **លោក ច័ន្ទ ភក្តី**<br>ប្រធានប្រតិបត្តិការ និងអភិវឌ្ឍន៍សមាជិកភាព អង្គការ គ.ស.ក |
| ១១:១០ – ១១:៥០ | **<u>គន្លឹះសំខាន់ៗ</u>៖ សមិទ្ធិផលសំខាន់ៗ របស់ គ.ស.ក ក្នុង ឆ្នាំ២០២២ និងផែនការប្រតិបត្តិសម្រាប់ ឆ្នាំ២០២៣**<br>• សមិទ្ធិផលសំខាន់ៗក្នុងឆ្នាំ២០២២<br>• គន្លឹះសំខាន់ៗនៃផែនការប្រតិបត្តិ និងថវិកា ឆ្នាំ២០២៣<br>**សំណួរ និងចម្លើយ** | **អ្នកស្រី លុយ ធារី**<br>ប្រធានកម្មវិធី អង្គការ គ.ស.ក |
| ១១:៥០ – ១២:០០ | **សរុបខ្លឹមសារ និងមតិបិទកម្មវិធី** | **លោក ទុំ វីរ៉ា** សមាជិកគណៈកម្មាធិការប្រតិបត្តិ និងនាយកប្រតិបត្តិ អង្គការមនុស្សចាស់កម្ពុជា |
| ១២:០០ – ១៣:៣០ | **ពិសារអាហារសាមគ្គីថ្ងៃត្រង់ និងកសាងទំនាក់ទំនង** | **អ្នកចូលរួមទាំងអស់** |

***ចំណាំ***៖ *ក្នុងនាមអ្នករៀបចំ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីអាស្រ័យលើករណីចាំបាច់របស់វាគ្មិន និងពេលវេលា។ កម្មវិធីនេះ មានបកប្រែជាភាសាអង់គ្លេស-ខ្មែរ។ សូមជម្រាបជូនជ្រាបថា៖ សកម្មភាព និងខ្លឹមសារសំខាន់ៗមួយចំនួនរបស់អ្នកចូលរួម នឹងត្រូវបានដកស្រង់ និងចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយដូចជា គេហទំព័រ និងបណ្តាញព័ត៌មានសង្គម។*

*http://www.ccc-cambodia.org/en/resources/event-archives*
*www.facebook.com/CCCsince1990*
*www.youtube.com/CCCambodia*